ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់ពីរ

ខ្សែ ១២

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណឺម៉ង់

គ្រិ. ឆ្នាំ ១៩២៨

ព. ស. ២៤៧១

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- ប្រវត្តិព្រះពុទ្ធរូបពុម្ព សាស្ត្រាចារ្យសេដេស ចាងហ្វាងសាលាបារាំងសែស នៅចុងបូព៌ាប្រទេសក្រុងហាណូយរៀបរៀងជាភាសាសៀមព្រះមហាពិទូរក្រសេមបណ្ឌិតនៅព្រះរាជបណ្ណាល័យប្រែជាភាសាខ្មែរ (ត-ចប់) ៧៧៣

២- អំពីលំនាំដើមហេតុនៃការដែលបានស្គាល់ប្រាសាទអង្គរ, លោរិកទរិគោ-លូបែហ្វ អគ្គលេខាធិការ នៅសាលាបារាំងសែសនាចុងបូព៌ាប្រទេស អធិប្បាយ ក្រុមការ ជុំអៅ ប្រែចេញជាភាសាខ្មែរ (ត-ចប់) . . . ៧៨២

៣- គតិលោក ឬច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត)

(អត្ថបទនេះ មិនមានចុះផ្សាយទេ ព្រោះមានបោះពុម្ពជាសៀវភៅហើយ)

# ប្រវត្តិព្រះពុទ្ធរូបពុម្ព

## សាស្ត្រាចារ្យ សេដេស

ជាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ក្រុងហាណូយ រៀបរៀងជាភាសាសៀម

ព្រះមហាពិទូរ ក្រាសេម

*បណ្ឌិតនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញជាភាសាខ្មែរ*

(ចប់)

---

*នៅមានទីសង្កេតមួយយ៉ាងទៀត ដែលអាចឲ្យកំណត់សេចក្ដីពាក់ទងគ្នារវាងព្រះពុទ្ធអម្បាលនេះ នឹងអាណាចក្រស្រីវិជ័យបាន នឹងអាចឲ្យកំណត់សម័យនៃព្រះពុទ្ធអម្បាលនេះបានផងថា ប្រហែលជាក្នុងពុទ្ធ-សករាជ ១៤៧០-១៧៥០ គឺព្រះពុទ្ធអម្បាលនេះប្រើអក្សរនាគរីជាអក្សររបស់ឥណ្ឌាប៉ែកខាងលើ សម្រាប់ចារឹកគាថា យេធម្មា ៗ ខនេះ ក៏បានដឹងជាក់ច្បាស់ហើយថា ក្នុងវាងពុទ្ធសករាជ ១២៥០-១៤៥០ មានព្រះសង្ឃឥណ្ឌាប៉ែចខាងលើនាំគ្នាទៅប្រដៅសាសនា នៅស្រុកកម្រទាស ស្រុកជ្វា និងស្រុកខ្មែរជាច្រើនលើក បាននាំយកទាំងអក្សរឥណ្ឌាខាងលើ ទៅប្រើក្នុងប្រទេសអម្បាលនោះផង ពួកប្រទេសនោះៗ ក៏ទទួលប្រើអក្សររបស់ព្រះសង្ឃដែលមកប្រដៅមួយគ្រាទៅ តែវេលាក្រោយមកត្រឡប់ប្រើអក្សរឥណ្ឌាប៉ែកខាងក្រោម (គឺខាងត្បូង) ដែលធ្លាប់ប្រើមក*

អំពីដើមនោះវិញ អាណាចក្រស្រីវិជ័យជាស្រុកតាំងនៅកណ្ដាល ពួកឥណ្ឌាខាងលើចុះមក តោងឈប់សម្រាកនៅទីនោះសិន ហើយទើបទៅកាន់ស្រុកប៉ែកខាងលើ និងកោះដទៃៗតទៅ ហេតុដូច្នោះមិនតោងសង្ស័យឡើយថា អាណាចក្រស្រីវិជ័យ និងមិនមែនជាអាណាចក្រដែលព្រះសង្ឃអម្បាលនោះនាំអក្សរឥណ្ឌាខាងលើទៅប្រើផង ចារឹកភាសាសំស្ក្រឹតនៅស្រុកកលាសានក្នុងកោះជ្វា (ព.ស. ១៣២១) ជាអក្សរនាគរីនោះ ជាព្រះរាជឱង្ការក្សត្រិយ៍ម្ចាស់ផែនដី ក្នុងរាជវង្សសៃលេន្ទ្រ ជារាជវង្សដែលដឹងពូជពង្សគ្នាថា បានគ្រប់គ្រងប្រទេសស្រីវិជ័យក្នុងវេលានោះ ។

អក្សរនាគរីបែបដែលប្រើនៅស្រុកជ្វា កាលពុទ្ធសករាជ ១៣០០-១៣៨០ នោះ នៅមានប្រើក្នុងប្រទេសកម្ពុជា (ខ្មែរ) កាលពុទ្ធសករាជ ១៤០០-១៤៨០ មួយវិញទៀតនៅមានព្រះពុទ្ធដែលចារឹកជាភាសាសំស្ក្រឹតដោយអក្សរនាគរី សម័យពុទ្ធសករាជ ១៤៨០-១៦៨០ នៅក្នុងប្រទេសភូមាទៀតជាតួយ៉ាង ព្រោះហេតុដូច្នោះ កាលរួមសេចក្ដីដូចបានពណ៌នាមកនេះ ក៏មានហេតុផលល្មមនឹងសន្និដ្ឋានឃើញថា ព្រះពុទ្ធជ្រោយមឡៃយូនោះ សាងឡើងក្នុងសម័យពុទ្ធសករាជ១៤៨០-១៨៨០ ។

បែបទី ៣ ព្រះពុទ្ធទី ៣ នេះ គ្រឿងតែងកាយនិងរូបទ្រង់ទ្រាយមានលក្ខណប្រហែលនឹងរូបចម្លាក់របស់ខ្មែរបុរាណ ព្រះពុទ្ធជំពូកនេះដែល

បានឃើញជាច្រើន ដូចយ៉ាងរូបទី ៩០ ខាងស្តាំ និងមេពុម្ព ទី ១ ខាងក្រោមនោះ អ្នកដែលបានឃើញរូបចម្លាក់បុរាណ ឬសិលាចារឹករបស់ខ្មែរហើយ រមែងដឹងបានជាប្រាកដតែម្តង រូប ៣ យ៉ាងប្រកបគ្នា គឺព្រះពុទ្ធអង្គគង់លើនាគ ១, ទេវតាមុខបួន ១, ស្ត្រី ១, រឿងនេះសាស្ត្រាចារ្យសេដេស បានអធិប្បាយទុកក្នុងសៀវភៅប្រវត្តិ ព្រះពុទ្ធរូបសម្រិទ្ធិខ្មែរហើយ ឯរូបទាំង ៣ នេះ ហៅថាព្រះអាទិពុទ្ធ ១, ព្រះពោធិសត្វលោកេស្វរ ១, ប្រាជ្ញាបារមិតា ១, រូបក្រោយនេះជាគ្រឿងសម្គាល់ថាព្រះពុទ្ធជាម្ចាស់អ្នកទ្រង់នូវបញ្ញាជាកំពូល រូបទាំងពីរដែលធ្វើឲ្យស្គាល់បានថា ពោធិសត្វលោកេស្វរ និង ប្រាជ្ញាបារមិតា ព្រោះរូបទាំង ២ កាន់របស់ផ្សេងៗគ្នា គឺព្រះលោកេស្វរដៃលើ ២ ដៃ ១ កាន់ផ្គាំ ដៃ ១ កាន់សៀវភៅ ឬក្រាំង ដៃក្រោម ២ ដៃ ១ កាន់ផ្កាឈូក ដៃ ១ កាន់កណ្ឌាទឹកអម្រឹត ឯប្រាជ្ញាបារមិតា ដៃសាំកាន់សៀវភៅ ឬក្រាំង ដៃឆ្វេងកាន់ផ្កាឈូក ម្យ៉ាងទៀតរូបទាំង ២ នេះ មានគ្រឿងសម្គាល់យ៉ាងឯទៀត គឺមានព្រះពុទ្ធរូបគង់តែនក្នុងជាកិរិយាសមាធិនៅត្រង់ដើងសក់ពីខាងមុខផង រឿងរូប ៣ យ៉ាងប្រកបគ្នានេះ ប្រទះឃើញអក្សរចារឹកខាងព្រះពុទ្ធសាសនារបស់ខ្មែរបុរាណជាច្រើន ដូចយ៉ាងពាក្យចារឹកជាភាសាសំស្ក្រឹតនៅភ្នំបន្ទាយនាង ជាខាងត្បូងទិក្រុមមឿងខណ្ឌមង្គលបូរី ខេត្តបាត់ដំបង ជាពាក្យនមស្ការដល់ព្រះអាទិពុទ្ធ ព្រះលោកេស្វរ និង

ប្រាជ្ញាចារមិតា ជាសេចក្តីគួរនឹងនាំយកមកចុះក្នុងសៀវភៅនេះផង ព្រោះរឿងនេះ មនុស្សនៅមិនទាន់ជ្រួតជ្រាបច្រើនណាស់ ។

## ពាក្យនមស្ការអាទិពុទ្ធ

នមោ ស្តុ បរមាទាយ វេរោចកាលាយ យោ ធរោ
ធមិសម្ភោគនិម្មាណកាយន៍ ត្រៃលោក្យមុត្តយេ ។

សូមនមស្ការព្រះបរមជិ (អាទិពុទ្ធ) អ្នកមានកាយដ៏ល្អិតបំផុតព្យោម (ខ្យល់) ជាអ្នកទ្រង់នូវកាយ ៣ យ៉ាង គឺធមិកាយ សម្ភោគកាយ និង និម្មាណកាយ ដើម្បីញ៉ាំងត្រៃលោកឲ្យរួចចាកទុក្ខ ។

## ពាក្យនមស្ការព្រះលោកេស្វរ

ភាតិ លោកេស្វរេ មូទ្ធ្នា យោ មិតាភញ្ជនំ ធរោ
មិតាស្និប្រកាសនាម កោដ្ឋោរ៍ ធរិធាទិវ ។

សូមនមស្ការព្រះ លោកេស្វរដ៏ទ្រង់នូវព្រះអមិតាភពុទ្ធអង្គ អ្នកមានពន្លឺកប់មិនអស់ ដោយត្បូង (ក្បាល) ភ្លឺរុងរឿងពណ្ណកាយជាងព្រះអាទិត្យនិងព្រះចន្ទ ដ៏ផ្សាយរស្មីបានល្អប្រមាណ ។

## ពាក្យនមស្ការព្រះប្រាជ្ញាបារមី

ប្រជ្ញាចារមិតាខ្យាយៃ ភគវត្យៃ នមោ ស្តុ តេ
យស្យាំសមេត្យ សរិជ្ញាសរិជ្ញត្វមុបេយុស ។

សូមនមស្ការដល់ព្រះភគវ័ត អ្នកដែលបានព្រះនាមថា ប្រាជ្ញាបារមិតា ជាអ្នកប្រទាននូវសារពើចំណេះទាំងពួងដល់អ្នក ដ៏មានញាណគ្រប់រូប ដែលដល់នូវព្រះអង្គជាទីពឹង ។

ប៉ុណ្ណោះក៏ល្មមយល់បានហើយថា ព្រះពុម្ពរូបបីយ៉ាងប្រកបគ្នានេះ ជារបស់ដែលគេកប់កាន់ច្រើន កប់កាន់ខ្លាំងយ៉ាងណា ។

ផែនទី ៤ ព្រះពុម្ពសុខោទ័យពុទ្ធសករាជ ១៧០០ ១៩០០ ព្រះពុម្ពជំពូកនេះច្រើនតែជាព្រះលីលា (គឺព្រះយាង) តែព្រះលីលានេះមិនបំពោះមានតែព្រះពុម្ពប៉ុណ្ណោះ មានទាំងសិតទាំងឆ្លាក់យ៉ាងដទៃ ៗ ក៏ជាព្រះលីលានេះជាច្រើនផងគ្នា ព្រះគ្រាលីលានេះជារបស់ដែលសៀមក្នុងសម័យនោះចូលចិត្តសាងណាស់ ព្រះពុទ្ធរូបចម្លាក់នៅវត្តមហាធាតុខេត្តសុខោទ័យ ជាតួយ៉ាងនៃព្រះគ្រានេះ ព្រះពុទ្ធរូបសម្រឹទ្ធិសរិទ្ធិគ្រាលីលា ២ អង្គ នៅវត្តបញ្ចមបពិត្រ (ក្រុងទេព) នោះ ប្រហែលជាបានមកអំពីវត្តមហាធាតុខេត្តសុខោទ័យនេះឯង ឬបើមិនមែនវត្តមហាធាតុក៏វត្តដទៃ តែគោងបានមកអំពីខេត្រនេះជាប្រាកដ ។

សេចក្ដីកប់កាន់របស់ជាតិសៀម ក្នុងការដែលធ្វើព្រះពុទ្ធរូបគ្រាលីលានេះច្រើនជាងគ្រាដទៃ មើលទៅមិនមែនដោយប្រទះដៃហើយក៏ចេះតែធ្វើទៅនោះទេ គឺក្នុងកាលពុទ្ធសករាជ ១៧៥០-១៨៥០ ជាតិសៀមកំពុងពង្រីកអាណាខេត្តឲ្យទូលាយចេញទៅបានគម្រោមប្រទេសជិតខាងឲ្យ

នៅក្នុងអំណាច ពួកសៀមនៅសុខោទ័យក៏ដេញពួកខ្មែរដែលនៅតាមដងទន្លេចៅពញា គឺនៅស្រុកស្រីលេ៉ជាដើម សៀមចូលគ្រប់គ្រងហើយតាំងគោលចាក់ព្រះពុទ្ធសាសនាក្នុងប្រទេសអម្បាលនោះ ចំណែកឯសៀមពួកដែលនៅស្រុកជៀងសែន និងស្រុកជៀងរ៉ាយក៏ដេញពួកមនចេញអំពីដងទន្លេកិង ដូចសៀមសុខោទ័យ ព្រះចៅកុមកំហែង[1] និងអ្នកដែលជំណាន់អំពីព្រះអង្គ បានសាងព្រះពុទ្ធរូបលីលានេះច្រើនណាស់ណា មិនដឹងបើនឹងកប់នឹងប្រមាណ ព្រះចៅមង្រ៉ាយច្បាំងឈ្នះក្សត្រិយ៍មននៅស្រុកលំពូន ហើយសាងក្រុងជៀងម៉ៃឡើង ក៏បានទ្រង់សិតព្រះពុទ្ធរូបលីលាឡើងជាច្រើនណាស់ដែរ គួយ៉ាង ព្រះលីលាដ៏ល្អដែលព្រះចៅមង្រ៉ាយសាងឡើងនៅស្រុកកុមកាមនោះ មាននៅក្នុងវិហារវត្តកាលកតស្រុកជៀងម៉ៃសព្វថ្ងៃនេះ គំនិតសៀមក្នុងសម័យនោះឃើញថា គ្មានអ្វីទីនល្អស្មើព្រះពុទ្ធរូបលីលា ទើបបានសាងច្រើនដល់ម្ល៉េះ ដែលខ្ញុំចូលចិត្តដូចនេះ ដោយបានឃើញព្រះពុទ្ធត្រាលីលា ដែលសៀមសាងឡើងក្នុងសម័យនោះច្រើនពន់ប្រមាណ ហើយមានទ្រង់ទ្រាយល្អ ៗ ផង ។

បែបទី ៤ ព្រះពុទ្ធតអំពីសម័យអយុធ្យាចុះមកនោះ គឺព្រះពុទ្ធដែលសាងឡើងក្នុងកាលក្រោយពុទ្ធសករាជ ១៩៥០ ព្រះពុទ្ធជំនាន់នេះ បើទោះបីជាវាយតម្លៃថា ថយថោកជាងព្រះជំនាន់មុនៗក៏ពិត តែជារបស់

១- ក្សត្រិយ៍នេះ ក្នុងវង្សពញារោង ។

មានតម្លៃក្នុងផ្លូវវិជ្ជាជាច្រើនណាស់ដែរ លក្ខណៈជាព្រះទ្រង់គ្រឿងបែប ដូច ៗ គ្នា នៅក្នុងផ្ទះកែវ នៅមានព្រះពុទ្ធរូបត្រាផ្សេង ៗ គឺអង្គុយខ្លះ ឈរខ្លះ ដើរខ្លះ ដេកខ្លះ ច្រើនធ្វើដោយដីខ្ពុកម្រ័ក្សបិទមាស ៗ

បែបទី ៦ នៅមានព្រះពុទ្ធមួយប្រភេទទៀតជាព្រះតូច ៗ ព្រះនេះគួរនឹងញែកចេញពីបែបដទៃហើយហៅថាព្រះគ្រឿងសម័យ ដែលកើតឡើងនៃព្រះពុទ្ធប្រភេទនេះ ជាការគម្រូនឹងកំណត់ឲ្យច្បាស់លាស់ទៅបានតែមួយប្រភេទទៀតជារបស់ចាស់បំផុត គឺបែបដែលហៅថាព្រះគង់ គឺអ្នកណាមួយមានព្រះនោះនៅនឹងខ្លួនហើយ អ្នកដទៃកាប់មិនមុត បាញ់មិនចេញ គេធ្វើឡើងនៅទីវត្ត មានវត្តមួយនៅក្នុងស្រុកលាំពូន ឈ្មោះជាវត្តព្រះគង់ ១ នេះ តាំងនៅខាងត្បូងស្រុកលាំពូន ខាងទិសឯជើង ចម្ងាយអំពីទ្វារចេញទៅប្រមាណ ១០០ សិន ព្រះវិហារដែលនៅឃើញសព្វថ្ងៃនេះជាបែបថ្មី តែកងឫសជារបស់ចាស់ សាងតាំងពីគ្រាមុនគ្រប់គ្រងស្រុកលាំពូននេះនៅឡើយ មុនសម័យព្រះចៅមង្រាយទៅបានជាធំក្នុងទីនោះ កាលពុទ្ធសករាជ ១៧៦០ កេងឧបោសថឬវិហារវត្តនេះគង់ជាបូជនីយស្ថានមួយកន្លែងក្នុងសម័យបុរាណ ព្រោះនៅឃើញមានព្រះពុទ្ធតូច ៗ ច្រើនណាស់ ជាព្រះពុទ្ធរូបគង់ក្រោមដើមពោធិព្រឹក្ស គេធ្វើនៅទីនោះជាអង្វែងមកហើយ ជីកទៅបានក្នុងបរិវេណវត្តនេះច្រើនរយ

ច្រើនពាន់ សូម្បីសព្វថ្ងៃនេះក៏នៅរកបានទាល់តែមានសម្តីថា ថាបើអ្នកណាមានបុណ្យហើយគ្រាន់តែកកាយដីនៅទីនោះ ក៏បានព្រះតែម្តង មិនចាំបាច់ជីកឲ្យជ្រៅទៅទេ ។

នៅមានព្រះគ្រឿងដទៃ ៗ ទៀតច្រើន សឹងមិនអាចនឹងកំណត់សម័យបាន ទាំងសព្វថ្ងៃក៏នៅមានមនុស្សបូលចិត្តសាងជាប្រក្រតី ។

រឿងព្រះពុទ្ធដែលបានពោលមកហើយ តាំងអំពីដើមដល់ត្រឹមនេះ ក៏ដើម្បីនឹងសម្តែងឲ្យឃើញថា ព្រះពុទ្ធទាំងឡាយ មានរឿងទាក់ទងនឹងប្រវត្តិព្រះពុទ្ធសាសនា លទ្ធិទំនៀមនិងវិជ្ជាជាដូចម្តេច ។

សូមឲ្យនឹកដល់ពាក្យទំនាយដែលថា ព្រះពុទ្ធសាសនានឹងអស់ទៅក្នុងកាលគ្រប់កំណត់អាយុ ៥.០០០ ឆ្នាំ ឬនឹងគង់នៅទៀត ២៥៣០ ឆ្នាំ តាំងតែឆ្នាំនេះជាដើមទៅ ក្នុងរឿងនេះបើប្រសិនជាកើតជាមហាឧទកភ័យ ដែលអាចនឹងបក់ផាត់យករបស់ផ្សេង ៗ ជាដើមថា រោងឧបោសថ វិហារ រូបព្រះសិត និងរបស់ដទៃៗ ទៀតទៅទាំងអស់ សុំឲ្យសល់តែព្រះពុទ្ធ ១ យ៉ាងប៉ុណ្ណោះ អ្នកប្រាជ្ញបុកណាគតិ សម័យក្រោយ ៥.០០០ ឆ្នាំទៅហើយនោះ កាលបានប្រទះឃើញព្រះពុទ្ធហើយនឹងអាចដឹងបានថា សាសនាដ៏ប្រសើរខ្ពង់ខ្ពស់បំផុតជាងសាសនាទាំងពួង ធ្លាប់បានមកចម្រើនរុងរឿងនៅក្នុងអាណាខេត្ត ដែលហៅថាបូពាទិសម្ពន់ហើយជាប្រាកដ គឺព្រះពុទ្ធអម្បាលនេះ នឹងសម្តែងឲ្យអ្នកប្រាជ្ញបុកណាគតិ ជ្រួត

ជ្រាបដល់ព្រះពុទ្ធអង្គដ៏ជាម្ចាស់សាសនា ដែលជាទីពឹងអាងរបស់ជនទាំងឡាយ ទាំងជាហេតុឲ្យដឹងដល់ចំណេះវិជ្ជាជាងរបស់ប្រទេសផ្សេង ៗ ក្នុងសម័យផ្សេង ៗ ផង ទាំងឲ្យដឹង ស្គាល់ទេវតាសំខាន់ ៗ ដែលពួកមហាយានសន្មឹម ៗ ពឹងអាងឡើងក្នុងសាសនាដែលមិនពឹងអាងទេវតាមកអំពីមុនផង បើអ្នកប្រាជ្ញបុរាណគតិ អាចប្រែសេចក្ដីពារីកសង្ខេបខ្លី ៗ ដែលគេចំណាំ តែពារីកនៅលើព្រះពុម្ពនោះបានហើយ គេក៏នឹងដឹងបានជាជាលទ្ធិសាសនាដ៏មានខ្លឹមសារច្រើន ។

កាលបើដូចនេះហើយ ក៏នឹងឃើញថា ព្រះពុម្ពជារបស់វិសេសមែន ហើយការទុកដាក់រក្សាព្រះពុម្ពជាការសំខាន់ណាស់ ក្នុងទីនេះខ្ញុំសូមអំណរដល់មហាជនអ្នកដែលបានប្រទះឃើញ ព្រះពុម្ពទុកជាមុនថា សូមឲ្យរក្សាទុកឲ្យល្អ ឬនាំទៅថ្វាយទុកនៅព្រះរាជបណ្ណាល័យកម្ពុជា នោះដើម្បីឲ្យអ្នកប្រាជ្ញពិចារណាមើលលក្ខណៈ ហើយធ្វើសេចក្ដីសន្និដ្ឋានឲ្យមុតមាំចុះ តែងជាសេចក្ដីអធិប្បាយពន្យល់ ព្រោះពុម្ពចំណាយផ្សាយជាប្រយោជន៍ទូទៅ ។

# អំពីលំនាំដើមហេតុនៃការដែលបានស្គាល់ប្រាសាទអង្គរ

## លោក វិកទ័រ គោល្វូបេហ្វ អគ្គលេខាធិការ

*សាលាបារាំងសែសនាចុងបូព៌ាប្រទេស អធិប្បាយ*

ក្រុមការ ជុំ - មៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យ ប្រែជាភាសាខ្មែរ

( ត - ចប់ )

---

*លុះដល់មកថ្ងៃ ១៥ ដេសម ឆ្នាំ ១៨៩៨ លោកប៉ូលឌូមែរ បានចេញការេត ១ ច្បាប់ តាំងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស[១] ក្នុងកាលនោះតំបន់ទន្លេសាបនៅជាដែនរបស់សៀមនៅឡើយ មានមន្ត្រីសៀមម្នាក់ស្ដីរាជការនៅសៀមរាប ចម្ងាយ ៤-៥ គីឡូម៉ែត្រពីអង្គរ ដើម្បីនឹងបានទៅមើលអង្គរនោះ អ្នកដំណើរត្រូវទៅសុំសេចក្ដីអនុញ្ញាតពីមន្ត្រីនេះ ឯកិច្ចការដែលសួរស្វែងរកនោះ បើមិនបានប្ដឹងដល់រាជការស្រុកបាងកកទេ នឹងធ្វើមិនបាន ។*

*សេចក្ដីតាំងប៉ុន្មាននេះ នាំឲ្យទទឹងទាស់ដល់សាលាដែលបានតាំងបង្កើត ហើយដែលមានរបៀបតាមសាលាបារាំងសែសនៅស្រុកអាតែន*

---

១- សាលាអ្នកប្រាជ្ញនេះមានលោក ហ្វីណូត៍ ជាចាងហ្វាងមុនបង្អស់ សាលានេះនឹងធ្វើបុណ្យអភិសេកគម្រប់ឆ្នាំទី ២៥ ជាឆាប់ហើយ ឯកិច្ចការរបៀបសាលានេះ បានបោះពុម្ពក្នុងប៊ុល្លីតាំងរាល់ឆ្នាំ ។

និងរ៉ូម នោះមានកិច្ចការដែលត្រូវធ្វើជាច្រើនក្នុងជាន់នោះ មិនទាន់បានចាត់ការរក្សាថែទាំឲ្យដូចជាសាលាឯទៀតផ្សេងៗក្នុងស្រុកក្រេក ស្រុកអីតាលី និងស្រុកអេស៊ីប នៅឡើយទេ សាលានេះគ្រាន់តែជាអ្នកទទួលការ ព្រោះរបស់ទាំងនេះនៅលើដីសៀម រាជការសៀមទទួលសាលានេះ ដោយគោរពខ្លាចប៉ុណ្ណោះ តែជាសំណាងណាស់ ស្ថានទាំងប៉ុន្មាននេះ មិនអាចនឹងឃាត់ឃាំងមិនឲ្យធ្វើការ ក្នុងវេលាដំបូងឲ្យបានចម្រើនឡើយ ។

ក្នុងឆ្នាំ ១៩០០ លោកកុំម៉ង់ដង់ លុណេត៍ ដឺឡាសុងគៀរ បានចូលទៅកាន់ក្នុងខេត្តសៀមរាប ដើម្បីគូរផែនទីនៃប្រាសាទទាំងឡាយ ហើយ ១ ឆ្នាំក្រោយនោះវេលាផុតរដូវភ្លៀង កូនសិស្សសាលា ២ នាក់ ឈ្មោះ ហង់រី ឌុយហ្វូរ និង សាលិការប៉ូ[១] បានទៅកាន់អង្គរធំ សំណាក់ក្នុងសាលា ១ ដែលបានសាងខ្លួនឯងនៅកណ្ដាលព្រៃស្វាយ និងព្រៃឬស្សី កិច្ចដែលទៅនេះគឺទៅកាប់ឆ្ការព្រៃដែលដុះបាំងប្រាសាទបាយ័ន ហើយពិនិត្យឲ្យសព្វគ្រប់នៃគំនូរនៅកំផែងជញ្ជាំង ។

តាំងពី ២ ឆ្នាំមុនប្រាសាទចម្លែកនេះ នៅបាត់ក្នុងព្រៃនៅឡើយ កំពូលមុខព្រហ្មដែលគេមិនដឹងប្រាកដ ជាមានមុខប៉ុន្មាននោះ មានវល្លិ៍ដុះព័ទ្ធ ហើយដើមឈើដុះពីលើ ទៅដល់ទីនោះ ដោយលំបាកខ្លាំង

---

១- ជាកូនឡូងលោកការប៉ូ ជាជាងចម្លាក់មានថ្វីដៃ ។

ណាស់ អស់ទាំងថ្នាក់ជណ្តើរបាក់បែកដាច់ពីគ្នា ហើយស្មៅដុះបាំងជិត មើលមិនឃើញ ស្លែនិងសម្បកពីងពាងធ្វើ ឲ្យរអិលជើងដើរពិបាក តោង យកដៃវែកព្រៃគ្រប់ជំហាន ដើម្បីកុំឲ្យបន្លាវាត់ត្រូវមុខ ឯផ្លូវដែលដើរ នោះមានដុំថ្មដេរដាសពាសពេញនាំឲ្យអ្នកទៅមើល ជៀសវាងដោយលំបាក មានព្រៃដុះចូលរហូតតាមផ្លូវចូលទៅបន្ទប់ធំ អស់ទាំងដើមពោធិ៍ ដើមសម្រោង ដើមរកាដុះក្នុងមួបក្រោមដំបូលប្រាសាទ ឫសឈើទាំងនេះទាក់ប្រទាក់គ្នាដូចជាក្រឡាមងមិនបេះអស់ ជ្រៀតចូលទៅក្នុងក្រហែងថ្មដែលប្រេះបែកនោះ នៅបន្ទាប់ព្រៃឈើទាំងនេះ បន្តិចឃើញក្បាច់ចម្លាក់ដេរដាស នៅលើជញ្ជាំងនិងសសរខាងនេះ មានរូបទេពអប្សរញញឹមប្រិមប្រិយ ខាងនោះមានរូបអ្នកតាចាំប្រាសាទ ខាងនាយទៅទៀតមានជញ្ជាំងដែលមានស្លែកាន់ក្រហមឬលឿង ហើយមានពស់សម្លាប់ កង្កែបស្ទុះរត់ដោយភ័យ ដែលឡើងទៅលើកន្លែងខ្ពស់នោះ ពិបាកដោយពន់ពេកណាស់ ហើយជាក្រោយដែលរអិល ជាក្រោយដែលសម្រាកកម្លាំងជាច្រើនដង ទើបឡើងបានដល់ទៅកំពូលប្រាសាទ នៅទីនោះឃើញតែពណ៌បៃតងដេរដាសនៅលើមុខព្រហ្មទាំង ៤ ៗ

អស់ទាំងសំបុត្រនិងកាសែតមានសៀរការប៉ូ ដែលគេបានបោះពុម្ពជាក្រោយដែលគាត់ស្លាប់នោះ ធ្វើឲ្យយើងឃើញសេចក្តីចម្រើននៃ

ការតាំងឡាយ[1]ចំពោះមុខ គាត់បានសរសេរ ពីថ្ងៃ ១៨ ដេសម ១៩០២ ថា ថ្ងៃល្អរបស់សាលា អំពីកាប់ក្តារ ១ កន្លែង នៅមុខប្រាសាទខាងជើង ហើយប៉ុន្មានថ្ងៃក្រោយនោះបន្តិច គឺថ្ងៃ ៣១ ដេសម ជុសលាងកំផែងជញ្ជាំង ខ្ញុំយកដែកគ្វាក់ឆ្កើសអាចម៍កណ្តៀ ដែលពួនជាប់បំបាត់ក្បាច់ចេញ ថ្ងៃស្អែកទើងបានឃើញក្បាច់ចម្លាក់នៅជញ្ជាំង ច្បាស់ល្អហើយ ហើយដល់មកថ្ងៃ ៦ ហ្វេវ្រិយេរ គាត់សរសេរថា ក្បាច់ជញ្ជាំងឃើញច្បាស់ឡើងហើយ ខ្ញុំមានសេចក្តីសោមនស្សជាបំផុតចិត្ត នៅវេលាដែលឃើញស្នូនិងដីបានបើកចេញ ហើយបានឃើញរូបចម្លាក់នោះមានសណ្ឋានដូចជារស់រវើកឡើង ។

មិនមែនជាការងាយជាដកបទេ ដែលលើកថ្មទៅដាក់នៅកន្លែងចាស់ ដោយថ្មទាំងនោះជួនកាលជាប់នៅទីងអ៊ីបន្តិច ។ អស់ទាំងគូលីរៀនទម្លាប់ប្រើរ៉ូឡូតាមបែបដែលបង្គាប់ឲ្យប្រើការ ដែលកាប់គាស់ឫសឈើនិងវល្លិចេញនោះ មិនមែនមិនលំបាកឡើយ ជួនកាលមែកឈើច្រូតទៅលើជញ្ជាំងមានដើមឈើដុះសង្កត់លើថ្ម ហើយធ្វើឲ្យថ្មបាក់បែកដោយកន្លែង តែធ្វេសបន្តិចនាំឲ្យស្រុតធ្លាក់កំពូល ១ ឬស្រុតបាត់ដំបូល ១ លុះការគាស់កកាយដុះលាងជញ្ជាំងជួនល្មម ទើងពិនិត្យមើលក្បាច់ដែលធ្លាក់បាននោះ ក៏តាំងចាប់រៀបចំថភយក ឯកិច្ចការដែលលាង

---

១- សាលិការប៉ូ អំពីប្រាសាទអង្គរ (បារីស ១៩០៨) ។

កញ្ចក់នោះ · គេបានរៀបកន្ទេល១ប្រក់ស្បូវបាំងហ៊ុមជិត នៅគរការសជក ដង្ហើមត្រឹម ៣.៣ អង្រ្កា ហើយលាន់ពេលយប់ ។

ពោះណាជាមានព្យាយាម និងបានសង្ក្រាតធ្វើទាំងអម្បាលនេះ ក៏ ព្រោះនោះនិងប្រាសាទទាំងនេះ ហាក់ដូចជារឹតតែមានការធំ ៗ ដែលត្រូវ តែធ្វើដល់ប្រាសាទបាយ័នជាច្រើនទៅទៀត មោងសៀវការប៉ុំបាន សរសេរក្នុងលិខិតទី ៨ របស់គាត់ជាដូចនេះ ។

ខ្ញុំឃើញថាយើងធ្វើការមានប្រយោជន៍ យើងបានរកឃើញអស់ ទាំងប្រាសាទ ដែលមានតែក្នុងក្រកនរក ដោយពិតដូចយ៉ាងលោកមូ- ហ៊ា, ដឹឡាពារត៍, ដឹឡាគ្រេ, អេម៉ូនីយេ ទើបបានរកឃើញ យើង បានរករបស់ទាំងនេះឃើញអស់ ហើយចាប់ធ្វើជាថ្មីឡើងវិញ យើង មានសេចក្តីអំណរនិងសេចក្តីស្ងប់ត្រពន់ពេកណាស់ ហើយក្នុងសំបុត្រជ- ដែលនេះ មានសេចក្តីជាដូចនេះ ខ្ញុំរឹងរឹតតែស្រឡាញ់ព្រៃស្បាតឡើង បន្តិចម្តង ៗ ។

លោកសង្ឃទាំងឡាយ កាលដើមមិនរស់ឡើយ ហើយក្រោយ មកចូលជួយក្នុងការនេះ បានជ្រៀតចូលទៅក្នុងចំណោមពួកគូលី ជួយ លើកថ្មចេញ នៅវេលាដែលលោកសង្ឃទាំងនេះទម្តកាត់កណ្តាលថ្ងៃ នោះ មើលទៅស្បង់ពីរហាក់ដូចជាឆេះភ្លើង មានលោកសង្ឃជាច្រើន ចាប់ឈើត្រុំ ហើយ អោងសៀវការរ៉ូ កំដៃទាំងម្ខាង ឯបាកំង

សែសទាំង ២ នាក់នេះទៀត ក៏ចាប់ជម្ងឺឈឺក្រោយនោះបន្តិចដែរ ដោយអំណាចកេចអាកាសមិនល្អ ហើយមុននឹងចូលឆ្នាំថ្មីមក ម៉ោនសៀរការ៉ូ កត់សេចក្ដីថាដូចនេះ យើងតាំងចាប់ឈឺហើយដោយអំណាចជម្ងឺគ្រុនចាញ់ ។

ឯការដែលបានធ្វើនោះ ក៏សាក់ខាននៅកណ្ដាលទី៖ ហើយម៉ោនសៀរ ឌុយហ្វួរ ក៏ទៅឯស្រុកបារ: ម៉ោនសៀរការ៉ូ ក៏ត្រឡប់មកក្រុងភ្នំពេញវិញ មានរទេះ ១៨ ផ្ទុកប្រដាប់ថតនិងពុម្ពមក ។

លុះដល់រដូវក្ដៅក្នុងឆ្នាំ ១៩០៤ គាត់ត្រឡប់ទៅអង្គរវិញ សេចក្ដីអំណរដែលគាត់នឹងបានឃើញព្រៃវិញនោះ នាំឲ្យគាត់សរសេរទុកប៉ុន្មានបន្ទាត់នេះដែលគេទុកដាក់គាត់ជាសិស្ស របស់សឹងហ្វូងស្កាដែលគេមិនស្គាល់ ។ ឯពាក្យដែលគាត់សរសេរនោះថាដូចនេះ "ខ្ញុំដេកលើពូករបស់ខ្ញុំដែលបាវខ្ញុំធ្វើ ហើយមានសេចក្ដីខ្ជិលច្រអូស ដោយអស់កម្លាំងនិងធ្វើការពីព្រឹក ក្នុងព្រៃទាំងអស់ស្ងាត់ជ្រៀប អស់បក្សីទាំងឡាយសម្ងំដេកអស់ មានតែសត្វអន្ទុប្រាណបន្លឺនូវតន្ត្រី មានសត្វតូច ៗ ជាអនេកដែលរស់ដោយថ្ងៃនិងដោយពន្លឺ សត្វទាំងនេះប្រគំតន្ត្រីព្ធកងរំពងជុំវិញសាលា តាមបែបភាសតែរៀងខ្លួន តាំងពីសត្វរៃធំដែលមានសម្លេងខ្លាំងទៅដល់សត្វរៃតូច ដែលមានសម្លេងស្រួចដូចជាម្ជុល សម្លេងសត្វទាំងប៉ុន្មាននេះនាំឲ្យប្រែហាក់អឹងកងក្នុងវព្រឹក្សាមនុស្សដែលសរសេរទាំងប៉ុន្មាន

បន្ទាត់នេះ មិនមែនជាមនុស្សមានកម្លាំងមាំមួនឡើយ គឺជាមេមានសៀ-ការប៉ុពីឆ្នាំ ១៩០៦ នោះឯង ការដែលរើករបស់បុកណានៅស្រុកអណ្ណាម គឺស្រុកយួននាំឲ្យគាត់អស់កម្លាំង ហើយការដែលគាត់បានធ្វើនោះក៏បាន ហើយស្រេច ទើបគាត់ដល់មរណភាព ២-៣ខែក្រោយនោះ នៅស្រុកព្រៃនគរក្នុងអាយុ ៣៤ ឆ្នាំដោយជម្ងឺមួល ការតាំងឡាយដែលមិស្សុង-ឌុហូរ-ការប៉ុបានប្រមូលផ្សំនោះ ពួកកុំមិស្សុងក្បាច់អលង្ការណ៍នៅប្រទេសឥណ្ឌូស៊ីន បានបោះផ្សាយឡើងក្នុងឆ្នាំ ១៩១០-១៩១៣ ហើយដាក់ចំណងជើងថា "បាយ័នអង្គរធំ" អស់តាំងរឿងរ៉ាវដែលជាប់នៅជញ្ជាំងប្រាសាទដ៏ប្រសើរបស់ខ្មែរ ។ល។"

ការដលបេះដងក្នុងរឿងរ៉ាវនៅកំផែងជញ្ជាំងនេះ ជាមានប្រយោជន៍ណាស់ ដើម្បីរិះរកសេចក្ដីស៊ីវិល័យរបស់ខ្មែរ លោកគ្រោសលីយេបានតែងសេចក្ដីដ៏ប្រសើអំពីជាតិខ្មែរក្នុងសៀវភៅលោក[1] ហើយគោលដើមនោះមិនអន្តរាយទៅណាឡើយ ឯរឿងរ៉ាវនៅកំផែងជញ្ជាំងអង្គរវត្តទាំងប៉ុន្មាននោះ ក្រៅពីក្បាច់អលង្ការណ៍សុទ្ធតែឆ្លាក់ជារឿងរ៉ាវទាំងអស់ ដែលមានរឿងខ្លះធ្វើតាមរឿងស្រុកឥណ្ឌូ ឯរឿងរ៉ាវដែលឆ្លាក់នៅប្រាសាទបាយ័ននោះបានចារឹកជាអក្សរធ្វើឲ្យយើងបានដឹងជាប្រាកដ អំពីពង្សាវតារក្នុងមហាវដ្ឋកាល គឺអំពីជ័យជំនះនិងអបរាជ័យ អំពីតយុទ្ធចំបាំងលើដី

១- ការរិះរកអំពីជាតិខ្មែរ (បារីស់ឆ្នាំ ១៩២១) ។

និងក្នុងសមុទ្រ  អំពីស្តេចយាងទៅកាន់ទីសំរេជនីយស្ថាន  អំពីសេចក្តីសោមនស្សរបស់បណ្តាកស្ត្រ  អំពីពិធីបុណ្យក្នុងសាសនា  រឿងរ៉ាវផ្សេងៗនោះឃើញធ្លាក់តគ្នា ១ ជុំ ១ គណ្ឌ ៗ មិនមែនជាតរឿងគ្នា  រហូតដូចជាកាំប្រាក់នោះឡើយ  ចម្លាក់ទាំងនេះបន្ទំនូវសេចក្តីគោរព  និងការសឹកសង្គ្រាមរបស់ស្តេចដែលព្រះព្រហ្មទ្រទ្រង់  ហើយដែលហាក់ដូចជាកាន់កាប់ការផែនដីនោះ  ដោយមានពួកកាន់សាសនាព្រះឥស្សរជួយផង  តើនរណាជាក្សត្រិយ៍នោះ  គឺជាយសោវរ្ម័នជាក្សត្រិយ៍ដែលគេថាបានសាងអង្គរធំបង្ហើយ  ហើយដែលចាប់គ្រងរាជ្យក្នុងឆ្នាំ ៨៨៩ នោះឬអ្វី  សេចក្តីមិនច្បាស់ប្រាកដមាននៅឡើយ  លើប្រាសាទបាយ័នព្រមទាំងក្សត្រិយ៍ដែលសាងប្រាសាទនេះ  ពិតមែនតែមានរឿងរ៉ាវខ្វះបញ្ជាក់ក្នុងសេចក្តីនេះ(១)  ហើយម្យ៉ាងទៀតក្នុងវេលាសព្វថ្ងៃនេះ  គេមិនអាចនឹងស្វែងយល់បានអំពីកេទព្រះដែលគេគោរពនៅប្រាសាទបាយ័ននោះ  សេចក្តីរិះរកទាំងនេះមិនអាចជ្រះស្រឡះឡើយ  ដោយការដែលរកឃើញជាខាងក្រោយ  រឹតតែនាំឲ្យបានសេចក្តីច្រើន  ជាប់ទៅលើចំណោទយ៉ាងជ្រៅរបស់ប្រាសាទបាយ័ន ។

---

(១) ក្នុងរឿងរ៉ាវពង្សាវតារអំពីស្រុកខ្មែរចាស់នោះមោនសៀរអេម្មូនីញេ បានតែង១ បរិច្ឆេទបរ៉ឹងសំខាន់អំពីក្សត្រិយ៍នេះ  ដែលគេអាចនឹងទុកដាក់បានថាជាស្តេចតម្កល់ក្នុងរឿងរ៉ាវរបស់ស្រុកអាយ ។

លក្ខណបញ្ញត្តិ នៃសេចក្តីសញ្ញាបារាំងសែសនិងសៀម កាលពីឆ្នាំ ១៩០៧នោះ មានសេចក្តីថា ត្រូវប្រគល់ឲ្យក្រុងកម្ពុជាវិញ ខេត្តសៀមរាប ១ សិរីសោភ័ណ ១ និងបាត់ដំបង ១ ដំបន់ទន្លេសាបនោះ ក៏ចូលទៅក្នុងដែនដែលបានមកវិញដែរ ក្រុងបារាំងសែសជាប់កិច្ចត្រូវថែទាំរក្សានៃប្រាសាទអង្គរ ។

តាមទំនាយរបស់អ្នកស្រុក ដែលជាគិតពរទុយគេសម្គាល់ឈ្មោះរីបា ដឹណាក បានទាកទុកក្នុងឆ្នាំ ១៣០០នោះថា៖ ក្រុងចាស់របស់ខ្មែរត្រូវមានប្រទេសដទៃមកសាងជាថ្មី បើសាងប្រាសាទអង្គរជាថ្មីឡើងវិញនោះ ជាការប្រព្រឹត្តអំពើល្មើសជាឧក្រិដ្ឋ១ ប៉ុន្តែគេអាចនឹងបញ្ឈប់សេចក្តីវិនាស នឹងការពារកុំឲ្យវិនាសដោយព្រៃឈើទៀតបាន ។

កាលក្នុងពង្សសៀមនៅឡើយ ប្រាសាទបុរាណទាំងនេះ បានប្រគល់ឲ្យលោកសង្ឃរក្សា អស់ទាំងលោកសង្ឃទទួលអ្នកដំណើរ និងអ្នកទៅមើលនៅក្នុងប្រាសាទ បោសសំអាតទីធ្លា ថែរនិងដណ្តើរ អុជទៀនធូបនៅមុខព្រះពុទ្ធរូប ដែលបានជួសជុលនិងលាបឡើងជាថ្មី សេចក្តីគោរពអ្នកបួសទាំងនេះ ផ្សាយដល់រូប ដែលបាក់បែកដោយចំណែក ៗ ហើយជួនកាលក៏ដើរទៅរក បំណែកព្រះហស្តនិងព្រះកេស ដែលបាក់បែកខ្ចាត់ខ្ចាយក្នុងព្រៃ ប៉ុន្តែសេចក្តីគោរពស្លូតត្រង់របស់លោកសង្ឃទាំងនេះ នាំឲ្យមានគ្រោះកាចដល់ប្រាសាទ គេដឹងថាការជួសជុលដែលមិន

ប៉ុនប្រសប់នោះ នាំឲ្យអន្តរាយដល់ប្រាសាទចាស់ ប្រទេសអាស៊ីលើកតែស្រុកជប៉ុនចេញនោះ មិនបានបោះបង់ក្បួនខ្នាតពេលឡើយ អស់ស្តូបតាំងឡាយដែលជាទំនើបថ្មី នៅស្រុកបៀរម៉ានី (ភូមា) និងនៅស្រុកស៊ីឡង់ (កោះលង្កា) បានជាតាំងដល់យើងជួនបរិបូណ៌ ឯខាងទ្វារអង្គរវត្តដែលកើតនេះ បានធ្វើអំពីថ្មកក់ ហើយកាលក្នុង ១០០ឆ្នាំមុននោះ គេបានរើសយកកំពូល ១ តាំងមូលដែលល្អជាងគេទៅឯស្រុកបាងកក ហើយយកទៅសង់នៅក្នុងកំផែងវត្ត ទំងមានសេចក្តីវែងឆ្ងាយពេកណាស់ ប្រសិនបើរៀបរាប់អំពីសេចក្តីដែលគេបានធ្វើ ឲ្យអន្តរាយទៅអង្គរវេលាមុន ដែលបាក់ងសែសមកដល់ បើដូចនេះគ្រាន់តែរៀបសេចក្តីតែ ១ ខក៏ជួនហើយ គឺអំពីប្រាសាទបាពួននៅមុខខាងកើតនៃប្រា-សាទនេះ មានកែប្រែ គឺបានប្រមូលផ្ដុំនូវដុំថ្មដែលខ្ចាត់ខ្ចាត់ចេញផ្តេសផ្តាស ដើម្បីជាពុទ្ធរូបដ៏ធំឡើង រឿងក៏រនោះ មានជាច្រើនទៅទៀតអំពីដែលគេបានធ្វើបំផ្លាញឲ្យខូចអន្តរាយនោះ លុះតែបាត់ការថែទាំផ្សេងលើប្រាសាទនេះ ទើបបានគង់ឋិតថេរតទៅទៀតបាន(១)ហើយមានវត្តជាច្រើន ទើបសាងថ្មីនៅក្នុងខេត្តសៀមរាប នោះបានយកថ្មចារិកទីងកន្លែងប្រជុំបុរាណមកសាង ។

---

១-អំពីក្បាច់ចម្លាក់ប្រាសាទនេះដែលគេលើកទុកជាជើគ ១ ក្នុងក្បាច់ចម្លាក់ខ្មែរ នោះឲ្យមើលរឿងក្បាច់នៅជញ្ជាំងបាពួន ដែលមោនសៀរល្វីហ្វិណូត៍បានតែងពីឆ្នាំ ១៩១០ (ប៉ុល្វីតាំង) ក្រុមកុំមីស្យុងក្បាច់អល័ង្ការណ៍ក្នុងប្រទេសឥណ្ឌូស៊ីន ) ។

ដោយអំណាចសញ្ញាត្រេតពីឆ្នាំ ១៩០៧ នោះសាលាបារាំងសែស នៅចុងបូព៌ាប្រទេស មានអំណាចជាអ្នកត្រួតត្រានៃអង្គរគ្មានអ្នកឯណា ១ នឹងរឹងទទឹងបាន ឥឡូវនេះ សាលានេះអាចនឹងចាត់ការរុករកតាមលំអាន ដែលមោនសៀរ ហង់រីប៉ារម៉ង់ទេ ជាចាងហ្វាងក្បាច់អលង្ការណ៍ បានតុប-តែងឡើងក្នុងការរុករកនៅស្រុកអាណ្ណាម ការដែលតាំងភ្នាក់ងារម្នាក់ឲ្យត្រួតត្រានឹងថែទាំរក្សានៃប្រាសាទបុរាណនេះ ប្រហែលជាមានប្រ-យោជន៍ពន់ពេកណាស់ ដោយហេតុនេះ ទើបសាលាបានរើសយកខ្លួនមោនសៀរសង់កុំម៉ៃ ដែលជាពួកក្រុមនៃសាលាដ៏ឈ្លៀវឆ្លាតរហ័សរហួន អង្គរក៏តាំងមានអ្នកថែរក្សាថែទាំនៅឃ្លាំងក្បាច់នៃប្រាសាទ តាមបែបដែលគេបានធ្វើ ឯប្រាសាទនៅក្រុងវែរសៃ និងនៅក្រុងហ្វុងតែណឺប្លូ ។

កិច្ចការជាដំបូងនោះ គឺកាប់ឆ្ការព្រៃអង្គរវត្ត និងជួសជុលកន្លែងនានាដែលខូចខាតបាក់បែកជាច្រើនជាងគេ ប្រាសាទយ៉ាងធំ ដែលមានស្រះនិងកំផែងនៅកណ្ដាល ដែលមានទីបរិវេណនិងទីធ្លាក្រាលថ្ម ទំហំធំជាង ១០០ ហិកតារ ក្នុងកាលនោះកប់បាត់នៅក្នុងព្រៃស្បាតនៅឡើយ ដូចកាលជាន់លោកឌូដារត៍ដឺឡាគ្រេដែរ គេដើរឆ្វេងនៅកណ្ដាលវល្លិនិងឫស្សី ត្រូវតែខំប្រឹងយ៉ាងយូរហើយអត់ធ្មត់ ទើបអាចនឹងសម្រេចតាមប្រូក្រាមដែលសាលាចាត់ចែងបាន គេខំផ្សំម្ដងៗដើម្បីផ្គុំនៅថ្មដែលក្រាលថ្មនិងទឿនដែលមានក្បាលនាគ ដុំថ្មដែលបាក់បង់នៅនោះ

រកឃើញឡើងវិញក្នុងស្នាមភ្លោះ បណ្ដោយតាមខឿន ហើយក្រោយបន្តិចតៗមក គេបានកាប់រំលំដើមឈើជម្រះស្មៅនិងកាត់វល្លិ៍ចេញ គេទុកតែដើមពោធិដែលល្អៗ និងដើមត្នោតខ្លះ អស់ទាំងទ្វានិងថែវនោះបានកងពីដើមឡើងវិញ នៅខ្លះតែគ្រឿងតុបតែងពីសំពត់ និងពីឈើលាបថ្នាំនិងលាបមាស អស់ទាំងរូបសិង្ហពីថ្មនិងរូបនាគនោះ នៅឈរលើកន្លែងដដែល ហើយឯស្រះនិងត្រពាំងនៃប្រាសាទនោះ ក៏បានដុសលាងសំអាតដល់បាត ហើយមានទឹកដក់នៅ ដុះដើមឈូកក្រហមសឈរហាន់ ។

ក្នុងវេលាជាមួយនេះ បានចាត់ចែងការនៅអង្គរធំ ដែលជាទីក្រុងធំមានជញ្ជាំងកំផែង បានកាប់ឆ្ការព្រៃក្នុងដំបន់ដែលហញ់ជាំងគេ ក្នុងព្រៃនោះដែលដុះបាំងទ្វារចូលទាំង ៤ តពីនោះគេបានទឹកទៅឯប្រាសាទបាយ័នទៀត ប្រាសាទនេះឃើញក៏បានដឹងហើយ គឺមានសៀរឌុយហ្វូរការប៉ូ បានគាស់កកាយកន្លែងខ្លះទៅហើយ ប៉ុន្តែរូបចម្លាក់នោះនៅកប់ក្នុងស្លែពណ៌បៃតងនៅឡើយ ឥតមានចាប់ធ្វើការអ្វីឲ្យមាំមួននៅឡើយទេ ការកាប់ឆ្ការព្រៃនៅប្រាសាទបាយ័ននោះ នាំឲ្យមានពាក្យនិន្ទាដូចកាលក្នុង ២៤ ឆ្នាំមុននោះ មានពាក្យនិន្ទាដល់លោកកុម៉ង់ដឺយាកូប៉ូបូទី ដែលបានកាប់ឆ្ការនេរកក្នុងស្រុករ៉ូម មានបណ្ដាជនខ្លះស្ដាយស្មៅដែលសត្វពពែធ្លាប់ស៊ីលើព្រះលានដែលឈើព្រៃដុសលប់ ហើយដែលមានលតាវល្លិ៍

ដុះក្រាលពេញទួទៅលើប្រាសាទបុកណានោះ  មិនតែប៉ុណ្ណោះ មានតាំង
អ្នកដំណើរដែលដើរតែងសេចក្តីបានបញ្ចេញនូវសេចក្តីប្រាថ្នាថា  សុំឲ្យ
បានឃើញព្រៃដុះលើប្រាសាទបាយ័នទៀត  ហើយឲ្យបានមានភាពថែប
ដូចកាលដើមវិញ ។

គួរតែរំលឹកសេចក្តីនេះថា ប្រាសាទបាយ័នជាគំរូ១នៃក្បាច់អលង្ការណ៍
ខ្មែរ មានប្រយោជន៍ដល់អ្នករៀនរចនា និងអ្នករៀនពង្សាវតារ ហើយ
ការដែលពិនិត្យមើលនោះ  លុះតែប្រាសាទតាំងមូលមានពន្លឺចាំងចូល
ច្បាស់ ទើបនិងពិនិត្យបាន  យើងបន្ថែមសេចក្តីនេះទៀតថា ក្នុង ២-៣
ឆ្នាំទៅមុខ ប្រហែលជាប្រាសាទបាយ័ននេះផ្លាស់ប្រែកង់កៅចេញ  ដោយ
គេបានត្រួតត្រាកាប់ឆ្ការព្រៃចេញ ។

វេលាដែលបានតាំងក្រសួងកជការក្បាច់លង្ការណ៍ជាថ្មី នៅអង្គរ
នោះ បានតាំងកជការមៅព្រៃជាបន្ទាប់ទៅទៀត ។

លោកសារលែតរ៉ូល  បានអធិប្បាយខាងចុងសេចក្តីរបស់លោក
អំពីរឿងកជធីតាម្នាក់ដែលផ្ដួលក្នុងព្រៃ  អំពីការដែលមានឡើងជាក្រោយ
កជធីតានោះក្បាក់ថា  មាននាងទេវកញ្ញា ១ បានធ្វើឲ្យព្រៃដុះឡើងជុំវិញ
ក្នុង ១៥ ម៉ែត្រ  ប្រហែលជាដែលគេគិតកាប់ឆ្ការស្បាត និងបន្ទាបចេញពី
ផ្លូវនិងពីទីធ្លា ហើយធ្វើឲ្យមានអាកាស ដល់ឈើតាំងឡាយនោះឯង ។

ឯខាងចំណែកអង្គរនោះ ត្រូវតែធ្វើព្រៃឲ្យបាត់ស្បាតជាដើម ហើយ

ផ្ការធ្វើផ្លូវ បោចស្មៅនិងបុសព្រៃកុំឲ្យលូតលាស់ច្រើនពន់ពេក និងរៀបចំឲ្យដុះតាមបែបយ៉ាងល្អ ក្រោយតមកទៀតព្រៃដែលបណ្ដាលឲ្យគ្រុនចាញ់ដែលមានជុំវិញប្រាសាទនោះ ត្រូវប្ដូរទៅជាសួនព្រៃធំដែលមានមនុស្សថែទាំដ៏ផ្ចិតផ្ចង់វិញ គឺហៅថាសួនអង្គរអស់ទាំងស្មៅបញ្ញើកំលែងដុះផ្ញើលើដើមឈើដែលគេត្រូវត្រាថែទាំទៀតហើយ ។ សព្វថ្ងៃនេះមានតែដើមឈើទាលធំៗ កងស្រលូតដុះជាជួរជេរជាសទៅ ។

ពួកអ្នកដំណើរទាំងឡាយ ដែលទៅដោយរថយន្តក្នុងរដូវត្រជាក់ ដើម្បីនឹងមើលប្រាសាទអង្គរ នោះមើលតែប្រាសាទធំៗ កំណត់ពីរថ្ងៃ ទើបបានចប់ឥតមានសម្រាក ក្នុងគ្រាឥឡូវដោយអំណាចការដែលបានធ្វើថ្មី នោះនឹងមើល ១ ស្របក់អាចចប់បាន ហើយបណ្ដាជនទាំងនេះមិនអាចនឹងសង្ស័យ អំពីសេចក្ដីខំសង្វាតដែលចម្រើនឡើង ដើម្បីការពារដល់ជនទាំងនេះ សេចក្ដីនឿយព្រួយឥតប្រយោជន៍ និងការពារនៃគ្រុនចាញ់ កុំឲ្យជិតដល់ផង(១) ។

ពិតមែនតែបានកែក្រែបបកេទព្រៃ ដែលដុះក្នុងប្រាសាទក្នុងប៉ុន្មានឆ្នាំមុននេះ ប៉ុន្តែការកាប់ផ្ការនេះមិនទាន់សព្វកន្លែងនៅឡើយ នៅមាន

(១) អំពីរឿងនេះយើងកត់សម្គាល់ អំពីដែលបានបង្កើតក្រុមសង្គណការ ១ ដែលហៅថា "ក្រុមសង្គណីការបណ្ដាមិត្រនៅអង្គរ" ហើយក្នុងពួកអធិបតីក្រុមនេះទាំងឡាយមានអោនសៀវសោរល់ក្រាវែល ១ បានជួយដោយកម្លាំងនិងគំនិតឥតគិតនឿយព្រួយជាច្រើន ដើម្បីឲ្យអ្នកដំណើរបានដឹងស្គាល់ ។

កន្លែងខ្លះ ដែលសល់នៅមិនបានកាប់ឆ្ការពោលដែរ វេលាណាដែលគេដេញចេញពីផ្លូវ ដែលអ្នកដំណើរទាំងឡាយបានដើរនោះ ហើយចូលទៅកាន់ផ្លូវរទេះដែលស្នាមកង់ស៊ីខូងជ្រៅទៅ មានតែរទេះគោជាតិស្រុកកាយយ៉ាងស្រាល ១ ទើបទៅរួច នោះគេនឹងឃើញព្រៃស្រោងត្រសុំសាខា មានម្លប់ត្រជាក់ល្អឥតប្រែប្រួល ប៉ុន្តែមានតែទិសខាងជើងខាងពាយព្យអន្លង់ធំដែលមានព្រៃឈើយ៉ាងល្អ ៗ លុះជិត ៗ ទៅ ទើបនឹងប្រាសាទទៅ ព្រៃទាំងនោះកាន់តែគ្រាក់ឡើង មិនពបសាដូចកន្លែងឯទៀត ព្រោះមានទឹកលិចជាញឹកញយ ព្រៃនេះនឹងល្អបានលុះតែកុំឲ្យមានអ្វីមកទើសទាល់វេលាដែលដុះឡើង ក្នុងតំបន់ទាំងនេះហើយដែលមានសត្វព្រៃជាច្រើន ដែលពួកអ្នកដំណើរ និងពួកអ្នករិះរកវិជ្ជាក្បាច់អលង្ការ បណ្ដេញចេញពីទីប្រាសាទទៅ បណ្ដាសត្វទាំងឡាយនោះមានសត្វទោចសម្លេងថ្ងួញថ្ងូរ សត្វរមាំងមានស្នែងទន្សាំ និងសត្វឈ្លូស សត្វមាន់ព្រៃក៏មានច្រើននៅទីនោះ ហើយឯខ្លារខិនក៏មិនក្រប៉ុន្មាន ។

លោកសង់កុំមែមរណភាពទៅ កាលពីថ្ងៃ ២៩ អាវ្រិល ១៩១៦ ដោយពោះជាតិស្រុកកាយសម្លាប់ អ្នកដែលជំនួសលោក គឺលោក

ហង់រីម៉ារ៉ែសាល់ ដែលជាអ្នកថែរក្សាកាន់កាប់ អង្គរសព្វថ្ងៃនេះ(១) ។

សំបុត្របករបស់លោក ហង់រីប៉ារម៉ង់ទីយេ មានសេចក្ដីថាការដែលលោកសង់កុម៉ៃ បានចាប់ធ្វើនោះ មិនទាន់សម្រេច ដោយលោកមរណកាលទៅ គេបានចាត់ការជាថ្មី លើប្រាសាទទាំងប៉ុន្មាននៅក្នុងព្រៃ គឺប្រាសាទបាពួនដែលគេបានកាប់ឆ្ការតាំងពីឆ្នាំ ១៩០៧ មក ប្រាសាទវិមានអាកាស ព្រះលានរបស់ស្ដេចគម្លង់ មានរូបអសុរនិងនាគមនុស្សជាច្រើនជួរ ប្រាសាទទេពប្រណម្យមានពុទ្ធរូបថ្មយ៉ាងធំនៅនោះ ដោយអំណាចការទាំងឡាយនេះ យើងនឹងបានសេចក្ដីចម្រើនជួនបរិបូណ៌យ៉ាងឆាប់ ក្នុងប្រជុំប្រាសាទទាំងនេះ ដែលអាចនឹងបានជាគ្រាប់ពូជនៃក្រុងដែលមានកំផែងជុំវិញ ហើយដែលលោកកុម៉ៃហៅថាកន្លែងប្រជុំនៃអង្គរធំ ប្រាសាទឯទៀតជាច្រើន ដែលនៅក្រៅកំផែងនោះ គេក៏បានរកឃើញក្នុងព្រៃទៀត គឺប្រាសាទតាកែវនិងបន្ទាយក្ដី ដែលមានស្រះ ១ ហៅថាស្រះស្រង់ ហើយក្នុងឆ្នាំមុនៗនេះគេបានរៀបរូបទេវតាទាំង ៥៤ ធំៗដែលនៅតម្រៀបនៅមុខទ្វារជ័យ តាមបណ្ដោយផ្លូវនោះឲ្យនៅលើកន្លែងសង់

១- លោកកុម៉ៃ បានចេញផ្សាយក្នុងប៊ុល្លីតាំងសាលាបារាំងសេសនៅចុងបូព៌ាប្រទេស អំពីការទាំងឡាយដែលបានធ្វើនូវអង្គរ សៀវភៅដែលលោកបោះពុម្ពនោះ បានជាអ្នកនាំផ្លូវនៃអ្នកដំណើរទាំងឡាយ ដោយមានរៀបរាប់ជួនល្អមអំពីទ្រង់ទ្រាយទីកន្លែង រូបថត ដែលលោកថតវេលាដែលលោកនៅធ្វើការនៅទីអង្គរនោះ បានយកទៅទុកនៅសារមន្ទីរ គីមេត៍ និងនៅសាលាបារាំងសេសនៅចុងស្រុកបូព៌ាប្រទេស (ហាណូយ) ។

ចាស់ដូចកាលពីដើមវិញ(១) ។

ដោយមានលោកគ្រូវែរណើរយេណោល ២ នាក់ជួយទំនុកបម្រុងផង គឺលោកអាល់ប៊ែរសារូត៍ និងលោក មូរីសឡុង នោះលោក ល៊ុយហ្វឹណូត៍ ជាចាងហ្វាងសាលា ដែលបានធ្វើការមកតាំងពី ២០ ឆ្នាំហើយ ។ ជាជំហូងបង្អស់ បានខំប្រឹងចាត់ចែងការឲ្យបានបម្រើនក្នុងរឿងកែវពន្យារគារនៃប្រជុំអគ្គ ។

មិនសូវមានអាទិត្យណា ១ ដែលទំនេរគ្មានរបស់អ្វី ១ ដែលរកឃើញថ្មីនាំនូវអំណរមកបង្អាក់ការ ធ្វើផ្លូវដែលកំពុងខំឡើយ គឺជួនកាលឃើញចារឹក ១ ថ្មីដែលគេមិនបានស្គាល់ ជួនកាលថ្មក្បាច់អ្វី ១ ដុំ ហើយជួនកាលឃើញមាឌរូប ១ ដែលគេបោះបង់ចោលជាច្រើនរយឆ្នាំនៅក្នុងព្រៃ ។

កាលពីឆ្នាំមុន គេបានគាស់ឃើញក្បាច់ចម្លាក់នៅប្របប្រាសាទនាគព័ន្ធ គឺជាប្រាសាទ ១ ដែលអ្នកដំណើរបានស្គាល់ច្បាស់ ដោយមានដើមជ្រៃដុះលបមានឫសគ្របព័ទ្ធជុំវិញ ក្បាច់នោះមានជារូបមនុស្សស្រាត អង្គុយលុតជង្គង់ជិះលើស្នាគ្នា រូបទាំងនេះប្រហែលជាឆ្លាក់ក្នាត់ទៅដោយការអ៊ីម៉្យាង ១ ដែលមិនទាន់ដឹងនូវឡើយ រូបទាំងនេះមានទឹកមុខហាក់ដូចជាមានសេចក្ដីបារម្ភ និងសេចក្ដីសង្ស័យមិលាយឡំជាមួយ

---

១- ការដែលលោក ហង់រីម៉ាក់សាល់ និងលោក សារល័បាត្តើរ បានធ្វើនោះ មានអធិប្បាយក្នុងប៊ុល្លីតាំងសាលាបារាំងសេសនៅចុងបូព៌ាប្រទេសឆ្នាំ ១៩២០ ។

គ្នា គឺជារូបឆើតជាងគេដែលរចនាដោយដៃក្បាច់ជាងរចនាខ្មែរ ប៉ុន្តែជាឥតសំណាងណាស់ ព្រោះរូបទាំងនេះបែកបាក់ជាបំណែកអស់ទៅហើយ តើគេអាចនឹងប៉ះប៉ុនឡើងវិញ ដោយយកបំណែកផ្សេង ៗ ដែលកប់នៅក្នុងដីក្រោមស្លឹកឈើស្លាប់សព្វថ្ងៃនេះនៅឡើយ មកផ្គុំបានឬទេ ប្រហែលជាយើងនឹងសង្ឃឹមបាន បើដូចនេះ ឃើញថាគេនឹងបញ្ចូលរឿងរ៉ាវ ១ ទំព័រថ្មីទៀត មកលើរឿងរ៉ាវដែលព្រៃនិងប្រាសាទអង្គរធ្វើឲ្យមានជាច្រើនជំពូកណាស់មកហើយនោះ ។

ក្រុងអារ៉ាយ នៅថ្ងៃ ២៨ អ៊ូត ១៩២២ ។

វិកធរ គោលូបេហ៍

– ចប់ –